គំនិតយុត្តិធម៌នៅកម្ពុជា
*Cambodia Justice Initiative*

-------------------------------------------------------------------------

# សេចក្តីប្រកាសព័ត៌មានរួម

## ស្តីពី សវនាការបឋមនៅលើ កាំង ហ្គេចអ៊ាវ ហៅ ឌុច

*ភ្នំពេញ ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩*

ប្រជាជនកម្ពុជាបានទន្ទឹងរង់ចាំយុត្តិធម៌អស់រយៈពេលជាង៣០ឆ្នាំមកហើយចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងនៅប្រទេសរបស់ខ្លួននៅចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី ៦ ខែមករា ឆ្នាំ១៩៧៩។ សវនាការបឋមជាលើកដំបូងទៅលើជនត្រូវចោទ **កាំង ហ្គេចអ៊ាវ** ហៅ **ឌុច** ដែលបានធ្វើឡើងនៅថ្ងៃនេះ បើកផ្លូវឱ្យមានការកាត់សេចក្តីជាប្រវត្តិសាស្ត្រលើកដំបូង ដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។

ការចាប់ផ្តើមនូវការកាត់សេចក្តីដែលទន្ទឹងរង់ចាំអស់រយៈពេលដ៏យូរ អាចបើកលទ្ធភាពឱ្យអង្គជំនុំជម្រះវិសាមញ្ញនៅទីបំផុតបង្ហាញប្រាប់ប្រជាពលរដ្ឋកម្ពុជា នូវដំណើរការនីតិវិធីប្រកបដោយតម្លាភាព និងយុត្តិធម៌ ដែលស្របតាមស្តង់ដារអន្តរជាតិយុត្តិធម៌ និងស្របតាមសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋកម្ពុជា។

អង្គការសង្គមស៊ីវិលដែលបានគាំទ្រសេចក្តីប្រកាសព័ត៌មាននេះ បាននិងកំពុងធ្វើសកម្មភាពក្នុងការជួយគាំទ្រការងាររបស់អង្គជំនុំជម្រះវិសាមញ្ញទៅលើការងារផ្សព្វផ្សាយ ការចូលរួមរបស់ជនរងគ្រោះ និងការផ្តល់សេវាកម្មផ្លូវច្បាប់សំរាប់តំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមស្វាគមន៍នូវជំហានជាប្រវត្តិសាស្ត្រជាលើកដំបូងនេះ។ យើងក៏ប្តេជ្ញាបន្តការងាររបស់យើងតទៅទៀត ក្នុងការជួយគាំទ្រជនរងគ្រោះដោយសាររបបខ្មែរក្រហម និង គោលបំណងរបស់អង្គជំនុំជម្រះវិសាមញ្ញ ហើយក៏សូមឆ្លៀតឱកាសនេះ ធ្វើការអំពាវនាវទៅដល់អង្គចៅក្រម ថ្នាក់ដឹកនាំរបស់សាលាក្តីនេះ ព្រមទាំងដៃគូរពាក់ព័ន្ធរបស់សាលាក្តីផ្សេងៗ នូវចំណុចដូចខាងក្រោមនេះ

១- យើងអំពាវនាវទៅដល់ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង ចាត់នូវវិធីសាស្ត្រជឿនលឿនមួយ ដើម្បីបង្ហាញនូវព័ត៌មានទាក់ទិននឹងការកាត់សេចក្តី **ឌុច** ដើម្បីធានា ប្រជាពលរដ្ឋកម្ពុជាអាចតាមដាន និងយល់ដឹងបានពេញលេញនូវដំណើរការរបស់សាលាក្តីនេះ និងយល់ដឹងបន្ថែមទៀតអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងជាពិសេស តួនាទីរបស់មន្ទីរស-២១ នៅក្នុងរបបខ្មែរក្រហមនោះ។

២- យើងអំពាវនាវទៅដល់ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង ឱ្យផ្តល់ការគិតគូរពេញលេញនូវសេចក្តីត្រូវការ និងតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងការចូលរួមនៅក្នុងសវនាការ និងអនុញ្ញាតឱ្យគេមានឱកាសចូលរួមទៅក្នុងដំណើរការកាត់សេចក្តីដោយពេញលេញ។

៣- យើងអំពាវនាវទៅដល់អង្គជំនុំជម្រះវិសាមញ្ញ ឱ្យធ្វើការខ្លាំងជាងនេះថែមទៀតក្នុងការជួយគាំទ្រដល់ការចូលរួមរបស់ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី ទៅក្នុងសវនាការ ដោយផ្តល់ដល់គេនូវជំនួយពេញលេញ ដែលអនុញ្ញាតឱ្យគេចូលទៅតុលាការ មានសេវាទីប្រឹក្សាច្បាប់ និងមានមេធាវីតំណាង។

៤- យើងអំពាវនាវដល់សហចៅក្រមស៊ើបអង្កេត ឱ្យពន្លឿនការស៊ើបអង្កេតសំណុំរឿង០០២ ដើម្បីជួយធានាថា សាក្សី និងជនត្រូវចោទដែលមានវ័យកាន់តែចាស់ទាំងអស់ មិនបង្កការរាំងស្ទះក្នុងការកាត់សេចក្តីនៅពេលខាងមុខទៀត។ យើងក៏សូមអំពាវនាវដល់សហចៅក្រមស៊ើបអង្កេត ឱ្យផ្តល់ព័ត៌មានសំខាន់ស្តីអំពីភាពជឿនលឿន និងការរីកចំរើននៃដំណើរការស៊ើបអង្កេតទៅដល់សាធារណជន ដើម្បីឱ្យគេអាចយល់ដឹង និងមានទំនុកចិត្ត ទៅលើដំណើរការនីតិវិធីនេះកាន់តែទូលំទូលាយថែមទៀត។

៥- យើងអំពាវនាវដល់អង្គបុរេជំនុំជម្រះ ឱ្យចាត់អទិភាពទៅលើការដោះស្រាយអំពីបញ្ហាខ្វែងគំនិតគ្នារវាងសហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងការស៊ើបអង្កេតទៅលើជនសង្ស័យបន្ថែមទៀត ដោយស្របទៅតាមគោលបំណងសំខាន់របស់អង្គបុរេជំនុំជម្រះនេះ ដែលត្រូវដើរតួនាទីជាយន្តការដោះស្រាយវិវាទ និងបញ្ចៀសនូវការពន្យាពេលនៃដំណើរការជឿនលឿនទៅមុខរបស់សាលាក្តីពិសេសនេះ។ យើងក៏សូមជំរុញឱ្យអង្គបុរេជំនុំជម្រះធ្វើការសំរេចប្រកបដោយឯករាជ្យ និងដោយមិនស្ថិតក្រោមសំពាធនយោបាយណាមួយ។

៦- យើងអំពាវនាវដល់ដៃគូរជាតិ និងអន្តរជាតិរបស់អង្គជំនុំជម្រះវិសាមញ្ញ ម្ចាស់ជំនួយ និងចៅក្រមសូមជួយដោះស្រាយបញ្ចប់នូវបញ្ហាចោទប្រកាន់អំពីអំពើពុករលួយនៅក្នុងសាលាក្តីពិសេសនេះដោយបង្កើតឱ្យមាននូវប្រព័ន្ធដែលគួរឱ្យជឿជាក់ និងឯករាជ្យ ដើម្បីដោះស្រាយបញ្ហាបណ្តឹងអំពីអំពើពុករលួយនាពេលបច្ចុប្បន្នប្រកបដោយប្រសិទ្ធិភាព ហើយព្រមទាំង បង្ការការពារ និងដោះស្រាយចំពោះការប្រព្រឹត្តខុសឆ្គងណាមួយ នៅពេលអនាគតខាងមុខទៀត។

យើងអំពាវនាវដល់ម្ចាស់ជំនួយនានា ឱ្យផ្តល់ថវិកាដល់អង្គជំនុំជម្រះវិសាមញ្ញឱ្យបានគ្រប់គ្រាន់ ដោយមានភ្ជាប់នូវលក្ខខណ្ឌគ្រប់គ្រង និងរដ្ឋបាលដ៏តឹងរ៉ឹង ដែលធានាឱ្យបាននូវស្តង់ដារសុច្ចរិតភាព និងប្រសិទ្ធិភាពប្រតិបត្តិការល្អប្រសើរជាងពេលបច្ចុប្បន្ននេះ។

ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនឹងចូលរួមសវនាការជាលើកដំបូងនៅថ្ងៃទី១៧ ខែកុម្ភៈ ២០០៩ ហើយ និង ផ្តល់បទអាចផ្តល់បទសម្ភាសន៍នៅក្នុងអំឡុងពេលសំរាកអាហារថ្ងៃត្រង់ នៅក្នុងបរិវេណអង្គជុំនំជម្រះ។

| លរ | ឈ្មោះ | តួនាទី/អង្គការ-សមាគម | លេខទូរស័ព្ទ |
|---|---|---|---|
| ១ | **លោក សុក សំអឿន** | នាយកប្រតិបត្តិអង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា (CDP) និងជាប្រធានសំរបសំរួលគណ:កម្មាធិការប្រព្រឹត្តិកម្ម (CHRAC) | ០១២ ៩០១ ១៩៩ |
| ២ | **លោក ធន សារាយ** | ប្រធានសមាគមអាដហុក (ADHOC) | ០១៦ ៨៨០ ៥០៩ |
| ៣ | **លោក ហង្ស ឆាយា** | នាយកប្រតិបត្តិនៃវិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ (KID) | ០១២ ៨៦៥ ៩១០ |
| ៤ | **អ្នកនាង សេង ធារី** | នាយិកាប្រតិបត្តិនៃមជ្ឍមណ្ឌលអភិវឌ្ឍន៍សង្គម (CSD) | ០១២ ២២២ ៥៩២ |
| ៥ | **លោក ឡុង បញ្ញាវុឌ្ឍ** | អ្នកសំរបសំរួលគំរោងយុត្តិធមិនៅកម្ពុជា (CJI) | ០១២ ៨៤៣ ៦៤៧ |
| ៦ | **លោកស្រី ពីង យុកហៀប** | នាយិកាប្រតិបត្តិនៃអង្គការជំនួយផ្នែកច្បាប់នៃ កម្ពុជា (LAC) | ០១២ ៨២៣ ៧៤៥ |